ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២២៧
ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២
សាលដីកា
លេខ : ៣៦ "ឈ"
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ
នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៣ ដោយមានសមាសភាពដូចតទៅ :

-ឯកឧត្តម [redacted] ជាប្រធាន
-លោកស្រី [redacted] ជាចៅក្រម
-លោក [redacted] ជាចៅក្រម
-លោក [redacted] ជាចៅក្រម
-លោក [redacted] ជាចៅក្រម
-លោក [redacted] ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញា

លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ២២ ក្រ.សេរ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤៦ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ រវាង :

-ដើមចោទ គណៈកម្មការវត្តព្រះជីវ័ធំ និងគណៈកម្មការទ្រទ្រង់សាលារៀនព្រះជីវ័ធំ មាន-ឈ្មោះ [redacted] សុខុម ,ឈ្មោះ [redacted] សន ,ឈ្មោះ [redacted] ឡាច ,ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] សារិន (ម្ចាស់បណ្តឹងសាទុក្ខ) មានទីលំនៅឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-ចុងចម្លើយ ឈ្មោះ [redacted] សាំង (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស ជាតិខ្មែរ មុខរបរធ្វើស្រែ អាយុ៥៧ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិកណ្តាល ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដីវត្តព្រះជីវ័ធំ ។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

-តាមបណ្ដឹងសាទុក្ខលេខ ២២៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ២២ ក្រអសរ ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១២ ត្រង់ចំណុចទាំងមូល។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ របស់តុលាការកំពូល។

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យនាយកបុគ្គលិកសាលារៀនព្រះជីវ័ធំ និងគណៈកម្មការវត្តជីវ័ធំថា តាំងពីសម័យដើមសាលាបឋមសិក្សាព្រះជីវ័ធំ គឺជាដីរបស់វត្តជីវ័ធំ ដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០០៨៦០ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៧ និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ព.វ ០០៨៥៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៧ តាំងពីដើមមកមិនមានទំនាស់កើតឡើងទេ។ តែក្នុងជំនាន់លោកតាចៅអធិការវត្តព្រះជីវ័ធំមុននោះ ព្រះនាម [redacted] ថាវ (បច្ចុប្បន្នលោកសុគតហើយ)។ ឈ្មោះ [redacted] សាំង បានសុំដីលោកចៅអធិការដើម្បីធ្វើស្រែចិញ្ចឹមជីវិត ដោយគ្មានធ្វើលិខិតស្នាមអ្វីទេ លុះដល់ពេលលោកតាសុគតទៅ ឈ្មោះ [redacted] សាំង បានប្ដឹងទៅឃុំ និងស្រុក ដើម្បីសុំធ្វើប័ណ្ណកម្មសិទ្ធិឱ្យខ្លួន តែឃុំ និងស្រុកបានបដិសេធពាក្យសុំនោះ ព្រោះតែឈ្មោះ [redacted] សាំង នេះបានរំលោភលើដីសាលារៀន និងដីរបស់វត្ត មកសុំយកជាកម្មសិទ្ធិផ្ទាល់ខ្លួន រហូតដល់ឈ្មោះ [redacted] សាំង នៅតែមានចេតនាទន្ទ្រាន និងបោះបង្គោលរំលោភយកដីជាកម្មសិទ្ធិរបស់សាលាបឋមសិក្សាព្រះជីវ័ធំ និងវត្តព្រះជីវ័ធំរហូតមកទល់នឹងបច្ចុប្បន្ននេះ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៩ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១-ច្រានចោលការទាមទារដីទំហំ ១២៥៣ ម២ ដែលស្ថិតនៅភូមិសឹង ឃុំកំពង់សឹង ស្រុកព្រះស្ដេច ខេត្តព្រៃវែង របស់ដើមចោទឈ្មោះ [redacted] សុខុម ,ឈ្មោះ [redacted] សន ,ឈ្មោះ [redacted] ឡាច ,ឈ្មោះ [redacted] ឃួម និងឈ្មោះ [redacted] សារិន ជាគណៈកម្មការវត្តព្រះជីវ័ធំ និងជាគណៈកម្មការទ្រទ្រង់សាលារៀនព្រះជីវ័ធំ ដែលមានមេធាវីតំណាងដោយអាណត្តិ គឺលោក [redacted] និងលោក [redacted]

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ របស់ចុងចម្លើយឈ្មោះ [redacted] សន [redacted] សារិន [redacted] ឃួម [redacted] សុខុម ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៩ "ឃ" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល។



Scanned with CamScanner

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ២២ ក្រIIសវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សន ,ឈ្មោះ [redacted] សារិន ,ឈ្មោះ [redacted] យូម និងឈ្មោះ [redacted] សុខុម ចោលជាអសារបង់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៩ “ឃ” ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហដើមចោទ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១២។ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងអំឡុងពេល ០១ ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

---

-បានឃើញបណ្ដឹងសាទុក្ខលេខ ២២៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ២២ ក្រIIសវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ត្រង់ចំណុចទាំងមូល។

-បានឃើញលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ របស់ម្ចាស់បណ្ដឹងសាទុក្ខ។

-បានឃើញឯកសារត្រៀមឆ្លើយតប ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣ របស់ចុងបណ្ដឹងសាទុក្ខ ឈ្មោះ [redacted] សាំង។

-បានស្ដាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះ កម្មវត្ថុទំនាស់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ សុំសំរេចតាមច្បាប់។

## ដំណាក់កាលទាញហេតុផលផ្ទាល់មាត់

-បានស្ដាប់ក្រឡាបញ្ជីអានលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹងសាទុក្ខ។

-បានស្ដាប់ក្រឡាបញ្ជីអានឯកសារត្រៀមឆ្លើយតបរបស់ចុងបណ្ដឹងសាទុក្ខ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យម្ចាស់បណ្ដឹងសាទុក្ខ បានធ្វើសេចក្ដីសន្និដ្ឋានថា ៖

រឿងនេះ មានបញ្ជាក់ល្អិតល្អន់ក្នុងមូលហេតុបណ្ដឹងសាទុក្ខរបស់ដើមចោទសព្វគ្រប់ហើយ អង្គហេតុ និងផ្លូវច្បាប់បានលើកឡើងអស់ហើយក្នុងសារណារបស់ដើមចោទ។ [illegible] ប្រគល់ដីទំនាស់ឲ្យជាប្រយោជន៍សាធារណៈ ហើយសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ដោយឥតបង្អិល។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់លិខិតបញ្ជាក់ពីមូលហេតុបណ្តឹងសាទុក្ខ និងសារណាឆ្លើយតបរបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ២២៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់លោក លី គីមលន់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍ក៏ដូចសាលាដំបូងខេត្តព្រៃវែងដែរ ដែលសំរេចច្រានចោលបណ្តឹងទាមទារដីទំនាស់ទំហំ ១.២៥៣ ម២ របស់សហដើមចោទ ដោយសំអាងលើលិខិតលេខ ០៨.២០១២ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកព្រះស្តេច និងតាមគំនូសបង្ហាញទីតាំងដីទំនាស់រវាងនាយកសាលារៀនបឋមសិក្សាព្រះជីវ័ធំ និងឈ្មោះ [redacted] សាំង ដែលថា ដីរបស់ឈ្មោះ [redacted] សាំង ដែលមានទំហំ ៣.៥២៧ ម២ មិនស្ថិតនៅក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ JX1.0022 ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៨៧ ហើយក៏ពុំជាន់គ្នាដែរ ព្រមទាំងមានដីបម្រុងនៅចន្លោះកណ្តាលទៀតផងនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា ៖

+លទ្ធផលនៃការស៊ើបអង្កេតរបស់គណៈកម្មការចំរុះ ដឹកនាំដោយក្រសួងទំនាក់ទំនងព្រឹទ្ធសភា-រដ្ឋសភា និងអធិការកិច្ច ទទួលស្គាល់ថា ដីរបស់សាលារៀនជាក់ស្តែងមានទំហំ ៥១.៥៦៤ ម២.

+ការចេញប័ណ្ណកម្មសិទ្ធិលើដីទំនាស់កន្លងមក ពុំមានលក្ខណៈត្រឹមត្រូវតាមនីតិវិធីឡើយ គប្បីបដិសេធ និងទុកសិទ្ធិអោយជនរងគ្រោះ ប្តឹងទាមទារជួសជុលការខូចខាតតាមនីតិវិធីច្បាប់។

-យល់ឃើញថា : សាលដីការរដ្ឋប្បវេណីលេខ ២២ ក្រIIសវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្តីមកនេះ មិនត្រឹមត្រូវនឹងគតិច្បាប់។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២២៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមច្បាប់។

២-បដិសេធសាលដីការរដ្ឋប្បវេណីលេខ ២២ ក្រIIសវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ទាំងមូល។

២៦២



Scanned with CamScanner

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២២៧ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មី។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤។

-ឯកឧត្តម [redacted] ប្រធាន

-លោកស្រី [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ ២០១៤

ប្រធាន

[redacted]